# ការជ្រើសរើសពូជជ្រូក

ពូជជ្រូកមាន៣ប្រភេទគឺ ពូជក្នុងស្រុក ពូជនាំចូល និងពូជកូនកាត់ ។ គេអាចជ្រើសរើសពូជណាមួយ មកចិញ្ចឹមអាស្រ័យតាមការនិយម ។

## ពូជនៅក្នុងស្រុក

### ពូជជ្រូកក្នុងស្រុកមានជ្រូកកណ្តុរ ជ្រូកកំពត និងជ្រូកដំរី ។

ជាពូជងាយស្រួលចិញ្ចឹម ធន់នឹងអាកាសធាតុ ជំងឺ និងមិនរើសចំណី តែពួកវាមានមាឌតូច និងលូត ធំធាត់យឺត ។

## ពូជជ្រូកនាំចូល

### ពូជជ្រូកនាំចូលមាន ជ្រូកយ៉កសៀរ ជ្រូកហាំសៀរ ជ្រូកឌុយរ៉ុក ជ្រូកប៊ឺកសៀរ និងជ្រូកឡែនដ្រេស

ជាពូជចិញ្ចឹមឆាប់ធំលូតលាស់ និងឆាប់បានលក់ តែពួកវារើសចំណីបន្តិច ។







## ពូជជ្រូកកូនកាត់



### ពូជកូនកាត់ជាពូជបង្កាត់រវាងបានាំចូលជាមួយមេ ក្នុងស្រុក។

គួរជ្រើសរើសជ្រូកកូនកាត់យកមកចិញ្ចឹម ព្រោះពូជនេះធន់ នឹង អាកាសធាតុក្នុងស្រុក ។ ជាពូជពិសេស ព្រោះរូបរាង

ខ្លួន និងការលូតលាស់កាត់ទៅរកបា រីឯការធន់នឹងជំងឺ និងការមិនរើសចំណីកាត់ទៅរកមេ ។

**តើត្រូវជ្រើសរើសកូនជ្រូកដូចម្តេច ?**

- រើសកូនជ្រូកណាដែលកើតចេញពីមេបា ដែលមានសុខភាពល្អ និងមានប្រភពច្បាស់លាស់។
- រើសកូនជ្រូកណាដែលមានជើងមាំ ប្រអប់ជើងធំៗ ត្រគាកសាយ ស្មាទូលាយ កវែងបន្តិច និងមានដងខ្លួនវែង ។
- រើសកូនជ្រូកដែលមានទំងន់ចាប់បី ៥ ទៅ ៧ គីឡូ និងមានអាយុចាប់ពី ៤៥ ថ្ងៃឡើង ហើយចេះស៊ីចំណី ។

(ដកស្រង់ចេញពីទស្សនាវដ្តីកសិករ របស់អង្គការសេដាក)